ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ
គណៈកម្មាធិការលទ្ធកម្ម
លេខ: 020/១៩ កសស.អល

**លទ្ធកម្ម ក.ស.ស**

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ប្រេងរំអិល សម្រាប់ម៉ាស៊ីន ផលិតនៅប្រទេសសាំងហ្គាពួរ ឆមាសទី ២ ឆ្នាំ ២០១៨

កំពង់ផែស្វយ័តក្រុងព្រះសីហនុសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថាៈ កំពង់ផែស្វយ័តក្រុងព្រះសីហនុនឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់ប្រេងរំអិល សម្រាប់ម៉ាស៊ីន ផលិតនៅប្រទេសសាំងហ្គាពួរ ឆមាសទី ២ ឆ្នាំ ២០១៨ ជូនកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

កំពង់ផែស្វយ័តក្រុងព្រះសីហនុបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃនិងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃនាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ ដែលមានអាសយដ្ឋានៈ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ចាប់ពីថ្ងៃ **០២** ខែ **តុលា** ឆ្នាំ **២០១៨** តទៅ រៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទំនាក់ទំនងលេខ **012 912 034** ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង **៤:០០ល្ងាច ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៨** ។

**ការបើកសំណើដេញថ្លៃ** នឹងប្រព្រឹត្តទៅនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ តាមអាសយដ្ឋានខាងលើ **វេលាម៉ោង ៤:០០ល្ងាច** ថ្ងៃទី **០២** ខែ **វិច្ឆិកា ឆ្នាំ ២០១៨** ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

*ថ្ងៃ សុក្រ ៤រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*
*ខេត្តព្រះសីហនុ, ថ្ងៃទី 28 ខែ ក.ញ្ញា ឆ្នាំ ២០១៨*

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាប្រធានអគ្គនាយក**
**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**លូ-គីមឈន់**

**ចម្លងជូន**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ